# ព្រះរាជាណាចក្រដូហាមី

ដូហាមី (Dohamey) គឺឈ្មោះព្រះរាជាណាចក្រមួយដែលបច្ចុប្បន្នស្ថិតនៅខាងត្បូងនៃប្រទេសបេនីន (Benin) ក្នុងទ្វីបអាហ្វ្រិចខាងលិច។ ព្រះរាជាណាចក្រនេះចាប់ផ្ដើមរីកចម្រើននៅស.វ.ទី១៧ រហូតដល់ស.វ.ទី២០។[១] នៅក្នុងប្រវត្តិសាស្ត្រនៃដូហាមី ស្ដេច Wegbaja គឺជាអ្នកដែលធ្វើឱ្យព្រះរាជាណាចក្រមួយនេះ មានការរីកចម្រើនខ្លាំង (រូបលេខ១)។

ព្រះរាជាណាចក្រដូហាមី នៅអំឡុងពេលនៃការដឹកនាំដោយ ស្ដេច១២អង្គ ផ្សេងៗគ្នា ដែលចាប់ពីឆ្នាំ១៦២៥ រហូតដល់១៩០០ គឺបានធ្វើឱ្យដូហាមី មានឥទ្ធិពល និងជាមហាអំណាចមួយនៅតំបន់ឆ្នេរសមុទ្រនៃទ្វីបអាហ្វ្រិចខាងលិច។ នៅក្នុងប្រវត្តិសាស្ត្ររបស់ដូហាមី គឺមានទាហានស្រីដំបូងដែលបង្កើតឡើងក្នុងរជ្ជកាលស្ដេច Ghezo ឆ្នាំ១៨១៨ ដល់១៨៥៨។ នៅដើមស.វ.ទី១៩គ.ស. កំណើននៃចំនួនទាហានស្រីមានការកើនឡើងជាង៣០ ទៅ ៤០ ភាគរយ នៃចំនួនទាហានសរុបនៃដូហាមី។[២] នៅចុងស.វ.ទី១៩ ក្រោមការដឹកនាំដោយស្ដេច Behanzin ទាហានទាំងនោះ ត្រូវបានបែងចែកជា៥ ប្រភេទផ្សេងៗគ្នា រួមមាន (រូបលេខ២)៖ ១. Huntresses ("Gbeto") ជាកងទ័ពស្រីដែលមានវ័យចំណាស់ ដោយមានជំនាញខាងបរបាញ់សត្វដូចជា ដំរី ខ្លា និងមានជំនាញខាងសំលាប់សត្វព្រៃ។ ២. Riflewomen ("Gulohento") ជាកងទ័ពដែលមានជំនាញខាង បាញ់សការុធ កាំភ្លើងវែង ខ្វី កាំបិត និងព្រួញជាដើម។ ៣. Reapers ("Nyekplohento") ជាទ័ពស្ត្រីដែលជំនាញខាងកាំបិតខ្វី វែង។ ៤. Archers ("Gohento") មានជំនាញខាងគប់លំពែង ព្រួញដែលភាគច្រើនជាក្មេងស្រី។ ៥. Gunners ("Agbalya") គឺជាទ័ពស្ត្រី មានពូកែខាងកាំភ្លើងធំ។[៣]

---

[១] https://www.britannica.com/place/Dahomey-historical-kingdom-Africa

[២] The women soldiers of Dahomey pedagogical unit 4 | Women (unesco.org)

[៣] The women soldiers of Dahomey pedagogical unit 4 | Women (unesco.org)

អត្ថបទដោយ៖ អេង តុលា

តាមរយៈនៃទីតាំងភូមិសាស្ត្រដែលមានភាពអំណោយផល ធ្វើឱ្យដូហាមី ងាយស្រួលវាយធ្វើសង្គ្រាម និងក្លាយជាអាណាចក្រនៅតំបន់ឆ្នេរ សមុទ្រ ដែលគ្រប់គ្រងលើតំបន់ Allada និង Whyda។ ចាប់ពីឆ្នាំ ១៧២០ រហូតដល់ឆ្នាំ ១៨៥២ តំបន់នោះ បានក្លាយជាការជួញដូរទាសករទៅឱ្យពួក អង់គ្លេស បារាំង និងព័រទុយកាល់។[៨]

អាបូមី គឺជាឈ្មោះ នៃរាជវាំងរបស់ ដូហាមី ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសបេនីន។ រាជវាំងមួយនេះ មានទំហំផ្ទៃដី៤៦ហិតាដែលមាន១០អាគារ កសាងនៅក្បែរគ្នា និងមានកំពែងដីជុំវិញ។ អាគារទាំងនោះ គឺតុបតែងតាមសិល្បៈវប្បធម៌ Aja-Fon ដែលធ្វើពីដីឥដ្ឋ ដោយមានការតុបតែងជាចម្លាក់សត្វតូចៗ និងសិល្បៈផ្សេងៗទៀត (រូបលេខ៣)។

Behanzin គឺជាស្តេចចុងក្រោយគេនៃព្រះរាជាណាចក្រ ដូហាមីមុនពេលដែលពួកអឺរ៉ុបបានមកដាក់អាណានិគមនៅស.វ.ទី១៩ ។

រាជវាំងនេះ គឺទ្រព្យសម្បត្តិដ៏សំខាន់មួយសម្រាប់ប្រជាជន ដូហាមី។ ទីតាំងរបស់ស្តេច Akaba និង ស្តេច Wegbaja គឺបែងចែកគ្នាដោយមានផ្លូវមួយ។ ក្នុងចំណោមអាគារទាំង១០ នោះមានអាគារចំនួនពីររបស់ Glele និង Guezo ត្រូវបានជួសជុល និងកែលម្អ ដោយគម្រោង World Monuments Fund ដែលសព្វថ្ងៃជាសារមន្ទីរប្រវត្តិសាស្ត្រក្នុងតំបន់ និងប្រជាជន ដូហាមី។[៩] ចំណែកឯអាគារផ្សេងពុំទាន់មានការជួសជុលនៅឡើយដែលនៅសភាពទ្រុឌទ្រោម និងមានគ្រោះថ្នាក់ខ្លាំង នៅពេលរដូវភ្លៀង។ គួរបញ្ជាក់ដែរថា រាជវាំងអាបូមី ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្នុងឆ្នាំ ១៩៨៥ ក្នុងទំហំ៤៧ ហិតា។[៦]

---

[៨] The true story of the women warriors of Dahomey (nationalgeographic.com)

[៩] Royal Palaces of Abomey | World Monuments Fund (wmf.org)

[៦] Royal Palaces of Abomey - UNESCO World Heritage Centre

អត្ថបទដោយ៖ អេង តុលា

សរុបរួមមក ដូហាមី គឺជាព្រះរាជាណាចក្រមួយដែលមានការរីកចម្រើនចាប់ពីស.វទី១៧ រហូតដល់ស.វទី២០ និងសំបូរទៅដោយទាហានស្រីយ៉ាងច្រើន។ ព្រះរាជាណាចក្រមួយនេះ មានរាជវាំងឈ្មោះ អាបូមី ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសបេនីនបច្ចុប្បន្ន។




រូបលេខ១៖ ផែនទីនៃព្រះរាជាណាចក្រដូហាមី

ប្រភព៖ https://www.nationalgeographic.com

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា




រូបលេខ២៖ទាហានស្ត្រីដូហាមី
ប្រភព៖ https://www.nationalgeographic.com





រូបលេខ៣៖ វាំងអាបូមី

ប្រភព៖ Unesco

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៤៖ រូបចម្លាក់ផ្ញីពីលោហ

ប្រភព៖ Metmuseum

អរិយធម៌ខ្មែរ
KHMER CIVILIZATION

## ឯកសារយោង

https://www.britannica.com/place/Dahomey-historical-kingdom-Africa

The women soldiers of Dahomey pedagogical unit 4 | Women (unesco.org)

https://www.metmuseum.org/

The true story of the women warriors of Dahomey (nationalgeographic.com)

Royal Palaces of Abomey | World Monuments Fund (wmf.org)

អត្ថបទដោយ៖ អេង តុលា